# ៤- រឿង ហាយ៉េង

## បទភាគគតិ

អញខ្ញុំក្រួញក្រាប សិរសាស្រពាប លុតលើកហត្ថា
ទសង្គុលី អភិវន្ទា នៃព្រះពុទ្ធជា
ឥស្សរភពត្រី ។

ព្រះអង្គឧត្តម លើសលើឥន្ទព្រហ្ម មូលមកភក្តី
ប្រកបប្រការ សម្ភាររិទ្ធី បរិបូណ៌បារមី
ពិសេសថ្កើងថ្កាន ។

បង្គំព្រះធម៌ ពិសេសមានអាថ៌ ជ្រៅពន់ប្រមាណ
ស្មោះស្មើភេត្រា ថ្លៃថ្លាមែនមាន បវរទិព្វញ្ញាណ
ផ្ទឹមផ្ទុកសព្វសត្វ ។

បង្គំព្រះសង្ឃ ប្រសើរឧត្តុង្គ ឧត្តមពេកក្លាត់
អាចនាំសត្វឆ្លង រំលងវាលវដ្ត ដល់ឋានអម័ត
បូរីនាយណាយ ។

ទើបខ្ញុំបង្គំ ទិព្វទេពឧត្តម សោឡសសួគ៌ា
សូមសុខសួស្តី សិរីទីឃា យុយឺនសុខសា
ប្បាយបរិបូណ៌បុណ្យ ។

ស្រេចខ្ញុំនឹងថ្លែង ដំណើរដំណែង ដំណាលពីមុន
មានក្សត្រមួយថ្លៃ ប្រពៃលើសលន់ គ្រប់គ្រងមហាជន
ក្រុងពារាណសី ។

ព្រះនាមព្រះបាទ ព្រហ្មទត្តនរនាថ លើសលើលោកិយ
ប្រកបជាយា អាឃិអគ្គមហេសី កបកល្យាណី
រូបរត្នសោភា ។

ព្រះស្នំសាវដៃ ពិសេសច្រើនក្រៃ សម្រាប់ក្សត្រា
គង់គាល់សព្វថ្ងៃ ក្រាស់ក្រៃគណនា ប្រដូចតារា
កររៀបរៀងរាយ ។

មន្ត្រីយោធា ស្រមណ៍ព្រាហ្មណ៍ភណា ចារចេះប្រាជ្ញប្រាយ
សម្រាប់មហាក្សត្រ ព្រហ្មទត្តរិទ្ធិសាយ ពលពាលទាំងឡាយ
អនេកសំខេយ្យា ។

ស្ដេចសោយរាជ្យស្កល់ ឥតកោលាហល រដ្ឋរាស្ត្រប្រជា
ទ្រង់ទសពិធរាជ្យ អង់អាចអាសា អាសូរករុណា
ចិញ្ចឹមរៀបរង ។

ក្សត្រក្សាន្តសោយរាជ្យ ថ្កើងព្រះអំណាច ឥតបីផ្ទឹមផង
ស្ដេចផ្ចាញ់សត្រូវ អាស្រូវយង់ឃ្នង ពុំអាចប្រឡង
សុខសល់លើសលន់ ។

កាលនោះមានមា ណពនៅភារា ក្សត្រថ្លៃមានបុណ្យ
ជាអ្នកទុគ៌ត ក្សិណក្សត់ទ្រព្យធន តែប្ដីប្រពន្ធ
និត្យនៅសព្វថ្ងៃ ។

ភរិយានោះណា មានរូបសោភា ស័ក្ដិសមល្មមល្មៃ
តែចិត្តនោះមិញ កំណាញ់ពេកក្រៃ ព្រៀងលានទីខៃ
គេពុំចូលចិត្ត ។

មានកាលមួយថ្ងៃ ចៅមាណពនៃ ទៅរកជញ្ជាត់
នឹងភរិយាប្រាណ ដោយដានកំសត់ ពិបាកពេកក្កាត់
ទុគ៌តក្រក្រៃ ។



កញ្ជើសោតធ្លុះ ដាចដាច់រលុះ ដោយមុំនោះនៃ
រីឯភរិយា ឥតអធ្យាស្រ័យ ពុំគន់រំពៃ
ថៃទាំឡើយហោង ។

ប្ដីតែងជញ្ជាត់ ដាក់ទៅជ្រុះបាត់ តាមមុំនោះផង
ឥតសព្វឥតសារ ឥតការជាម្ដង ហេតុឥតចិត្តចង
រំពឹងនាំពា ។

ជញ្ជាត់រៀងទៅ ដួចដល់សំពៅ ធារធំមហិមា
រីនាយសំពៅ និត្យនៅភរិយា មើលពីភេត្រា
យល់កញ្ជើធ្លុះ ។

នាងនាយភេត្រា ស្រដីទៅថា នាងជញ្ជាត់នោះ
ម្ដេចពុំគិតធ្វើ កញ្ជើនាងធ្លុះ យកអ្វីចុកចុះ
សោះវាលិចបាន ។

ក្សិណនាយសំពៅ គ្រោធក្រៃថាទៅ នឹងភរិយាប្រាណ
បើចេះដូច្នោះ មឹងចុះទៅថ្កាន កាន់កញ្ជើបាន
ជាប្រពន្ធវា ។

អញនឹងប្ដូរយក ប្រពន្ធវាមក នៅលើភេត្រា
ជាប្រពន្ធអញ រីឯវិញហោងណា ក្បិតចៅជាងវា
បង្គាប់ជូនថៃ ។

នាងស្ដាប់ប្ដីថា នឹងដូរភរិយា ឯងឱ្យទៅគេ
ដោយពាក្យពុំស្រួល ពុំគួរបើជេរ ខ្លួនគ្មានទោសទេ
ម្ដេចចងទោសា ។

ទើបនាងឆ្លើយទៅ កាននាយសំពៅ ជាប្ដីអាត្មា
ពាក្យខ្ញុំទ្រគោះ លើសលស់ត្រង់ណា ក៏ដល់អ្នកជា
ប្ដីពុំចូលចិត្ត ។

នឹងយកខ្ញុំទៅ ជូរមាណពនៅ កាន់ឈ្នាងជញ្ជាត់
បើអ្នកជូរទៅ ខ្ញុំទៅនឹងគាត់ ខ្ញុំសោតគ្មានមាត់
ប្រកែកថាអ្វី ។

ទើបនាយសំពៅ ស្រេចស្រែកហៅទៅ បុរសនោះថ្មី
ថាចៅហ៊ានជូរ ប្រពន្ធឬអ្វី មកអាយស្រដី
ឱ្យជាក់នឹងគ្នា ។

មាណពជញ្ជាត់ ឮនាយនោះគាត់ ស្ដីជូរភរិយា
ខ្លាចខ្លួនពុំហ៊ាន ទៅថ្កានភេត្រា នាយនោះវែងជា
ហៅខ្ជាន់ៗទៅ ។

ទើបមាណពនោះ ទន្ទបចូលស្មោះ ឡើងលើសំពៅ
ទាំងប្ដីប្រពន្ធ អង្គុយនិត្យនៅ ទៀបនាយសំពៅ
ស្រដីទៀតថា ។

ចៅអើយកុំយូរ មកយើងនឹងប្ដូរ ប្រពន្ធផងគ្នា
អញឱ្យប្រពន្ធ អញទៅចៅណា ចៅឱ្យភរិយា
ចៅមកអញហោង ។

មាណពកំសត់ ស្ដាប់យល់ទាស់បទ ពុំហ៊ានសារសង
នាយនោះវែងរូន ជូនៗច្រើនដង ថាហើយថាផង
ជាច្រើនភាសា ។

ទើបមាណពនោះ ថាតាមចំពោះ ចិត្តអ្នកហោងណា
ខ្ញុំជាអ្នកហោច ត្រមោចកំព្រា ឥតបើនឹងថា
ទាស់ទែងសេចក្ដី ។



នាយសំពៅស្ដាប់ អស់អាថ៌សារសព្ទ ត្រេកអរបេតី
ក្បោមក្បាន្តកន្លង ដណ្ដឹងឃ្មាតខ្ទី ថាហៃប្អូនស្រី
ឯណោះសោតហោង ។

ថានាងប្អូនស្និទ្ធ ស្នេហ៍ស្មាលចូលចិត្ត ព្រមមូលនិងបង
ឬមួយពុំមូល ពុំចូលចិត្តបង ចូរចៅសារសង
ឥឡូវនេះណ៎ា ។

ឯមេកញ្ញើ ធ្លុះអរលលើ ចង់នាយនាវា
សើចហើយញញឹម មើលចុងនេត្រា ឱនហើយទើបថា
គួពីព្រេងហោង ។

ឯនាងភរិយា ចៅនាយភេត្រា ស្ដែងស្ដាប់សារសង
ប្ដីប្ដូរផ្ដែផ្ដាច់ ពាក្យពេចន៍ជាម្ដង នាងចរចុះផ្គង
ពីលើភេត្រា ។

តែស្បៃនៅក នាងដើរចុះមក កាន់ប្ដីកំព្រា
ទ្រព្យធនពុំយក ដិតមកអាត្មា នាងឈោងប្រវា
កញ្ញើកាន់ទៅ ។

បោចបានសម្រា មកចុកជិតភ្លាម ពិតពុំឱ្យសៅ
នាងកាន់តាមប្ដី ជញ្ជាត់តាមស្មៅ បានស្រេចទើបទៅ
ឋានប្ដីនោះណា ។

លុះដល់លំនៅ នាងដណ្ដឹងទៅ កាន់ប្ដីនាងថា
អ្នកអើយអស់ផ្ទះ រៀងខាងនេះណា ជាញាតិការ
សន្ដានផៅពណ៌ ។

ឬជាព្រៀងលាន ត្បិតខ្ញុំពុំមាន ដឹងញាតិនិមល
បើអ្នកឯណា ជាញាតិបវរ ព្រៀងលានស្មោះស
អ្នកប្រាប់ខ្ញុំវ៉ា ។

ប្ដីឆ្លើយរឹងទៅ នាងអើយញាតិផៅ បងគ្មានទេណា
សឹងតែព្រៀងលាន នៅឋានទៀបគ្នា សព្វថ្ងៃកំព្រា
គ្មានបងប្អូនឡើយ ។

នាងឮប្ដីថា ឥតញាតិវង្សា កំព្រាច្បោះហើយ
ហេតុនាងសប្បុរស យកគេជាត្រើយ នាងពុំគិតឡើយ
កំសត់អាត្មា ។

នាងយកត្រីនោះ ឱ្យប្ដីនាងស្មោះ ជូនចែកគ្រប់គ្នា
តិចៗគ្រប់មុខ អ្នកស្រុកនៅនា ព្រៀងលានស្គាល់គ្នា
ខេត្តខាងលំនៅ ។

ប្ដីសោតទៅស្មោះ ដោយប្រពន្ធនោះ បង្គាប់ប្រដៅ
កាលនោះព្រៀងលាន ខាងឋានលំនៅ សឹងគិតថាថៅ
នេះដែលឯណា ។

សប្បុរសដូច្នេះ ផ្ញើលអ្វីម្ដងនេះ ជូនយើងគ្រប់គ្នា
សព្វដងកំណាញ់ កន្រ្ទីសប្ញស្សា ឥឡូវម្ដេចជា
សប្បុរសពេកក្រៃ ។

អ្នកផងគិតហើយ ពិតពុំលង់ឡើយ មានកាលមួយថ្ងៃ
គេដើរទៅលេង និងមាណពនៃ យល់នាងប្រពៃ
មានរូបសោភា ។

ទើបគេគិតថ្មៃ ថាថៅនេះនៃ គាត់បានភរិយា
ទៀតទើបសប្បុរស ពុំដូចសព្វគ្រា នាងនេះលក្ខណា
មារយាទហ្មត់ហ្មង ។

មានកាលមួយថ្ងៃ មាណពទៅព្រៃ រកកាប់ឧសចង
បាច់បានរែកមក ដូចកាលសព្វដង រីឈើនោះផង
ពុំឈើខ្ចីខ្ជា ។

សឹងឈើប្រពៃ មែនមានតម្លៃ ក្លាំពាក់ក្រឹស្នា
នាងយល់ឧសប្ដី បានពីព្រឹក្សា សឹងឈើជាៗ
មានៗតម្លៃ ។

នាងគិតឯងថា ប្ដីអញនេះណា បានឈើប្រពៃ
ពុំស្គាល់ជាឈើ នោះមានតម្លៃ យកមកសព្វថ្ងៃ
ដុតដូច្នេះណា ។

សមឈើនេះមាន ក្រាស់ក្រៃនាឋាន អាយឯងទើបជា
ឱអស់អ្នកផង ពុំស្គាល់ក្រឹស្នា ក្លាំពាក់យកជា
ឧសឥតគិតឡើយ ។

ទើបនាងនារី ដណ្ដឹងទៅប្ដី ថាហៃអ្នកអើយ
ឧសនាព្រៃអាយ អស់តែម្ល៉េះហើយ ឬមួយនៅឡើយ
អ្នកប្រាប់ខ្ញុំវ៉ា ។

ប្ដីឆ្លើយរឹងទៅ មានច្រើនក្រៃនៅ នាព្រៃព្រឹក្សា
យកបានជារយ រទេះក្ដីណា ពុំអស់ប្អូនភ្ងា
នាងនឹងគិតថ្វី ។

នាងឮច្បោះណា អរឥតគណនា សំណេះនឹងប្ដី
ច្បោះអ្នកទៅរក យកមកទៀតខ្មី ឱ្យអស់អំពី
ព្រៃនោះឯងហោង ។

នឹងជួលរទេះ ញាតិជិតនៅនេះ ដឹកទុកជាម្ដង
ប្ដីថានាងនឹង យកឧសថ្វីផង បើអស់សឹមបង
រកមកទៀតណា ។

ទើបនាងឆ្លាស់ឆ្លើយ ថាអ្នកប្ដីអើយ ឈើនេះឈើជា
សឹងមានតម្លៃ ក្លាំពាក់ក្រឹស្នា អស់អ្នកភេត្រា
គេទិញយកទៅ ។

ឈើនេះខ្ញុំស្គាល់ ជាក់ឥតពិភាល់ អស់អ្នកសំពៅ
គេទិញមិនលែង ខ្ញុំឯងឃើញនៅ គេទិញនាំទៅ
ស្រុកចិននាយណ៎ា ។

បើយើងបានហើយ យើងគិតអ្វីឡើយ លក់តែក្រឹស្នា
ភ្លាំពាក់ប្រពៃ យកថ្លៃមកណា ទិញព្រៃកាសា
សំពត់ជាតិ ។

តាមតែចិត្តជ្រើស ចិត្តនឹងស្រាល់រើស យកប្រាក់មាសស្ពី
ដោយចិត្តស្រឡាញ់ ចង់ទិញអ្វីៗ អ្នកទៅរឹងខ្មី
តាមពាក្យខ្ញុំថា ។

ប្ដីឮថ្មោះនៃ អរឯងពេកក្រៃ ក្រទីក្រទា
បានម្រែកសង្រែក រែកទៅម្នីម្នា ដឹងកាំបិតព្រា
ចូលទៅក្នុងព្រៃ ។

កាត់គរទុកស្រេច ចងចោលជាបាច់ រែកមកពីថ្ងៃ
ហើយប្រាប់ភរិយា ប្អូនអើយឧសថ្លៃ កាត់គរនៅព្រៃ
ច្រើនក្រៃក្ដាត់ណ៎ា ។

រែកមកនេះហោង តាមកម្លាំងបង ទើបនាងភរិយា
រកជួលរទេះ ដឹកនាំក្រឹស្នា ភ្លាំពាក់ជាៗ
ពីព្រៃនោះនៃ ។

គរទុកនាស្ថាន នោះហើយទើបមាន ពាណិជ្ជទីទៃ
មកទិញក្រឹស្នា ភ្លាំពាក់ប្រពៃ នាងថ្លឹងកាត់ថ្លៃ
ឥតល្អៀងឡើយណ៎ា ។

ហេតុនាងនារី ដឹងអស់អំពី កាលនាងនៅជា
ប្រពន្ធនៃចៅ នាយភារភេត្រា ឥតឈ្មួញណាៗ
បំពោតបានឡើយ ។



លុះឈ្មួញទិញបាន ពីនាងកល្យាណ គេយកទៅហើយ
នាងរៀបទុកទ្រព្យ ផ្ទួរផ្គាប់ជាត្រើយ ពិតពុំលង់ឡើយ
រណ្ដាប់ត្រឹះឋាន ។

ចាយចាត់រៀបរក៏ លោះខ្ញុំកំដរ ប្រកបធនធាន
អ្នកផងចេញចូល នាងសោតថ្កើងថ្កាន សម្បត្តិមូលមាន
អនេកទ្រព្យា ។

ប្ដីនាងនេះនៃ បានស្គាល់ចៅទៃ ស្គាល់ព្រះស្គាល់ពញា
អ្នកផងរាប់អាន ត្បិតបានទ្រព្យា កបនូវលក្ខណា
នាងនោះប្រពៃ ។

ទើបនាងនារី ស្រដីនឹងប្ដី ថាអ្នកសព្វថ្ងៃ
ខ្ញុំចង់ឱ្យអ្នក រៀនរត់ឱ្យវៃ ឱ្យរួសឆាប់ក្រៃ
ដូចចិត្តចិន្ដា ។

ក្ដីសោតឆ្លាស់ឆ្លើយ ថាហៃនាងអើយ បងឥតបើថា
តាមចិត្តប្អូនហោង អញបងបានជា ម្ល៉េះត្បិតនរណា
មិនត្បិតប្អូនស្រី ។

លុះថ្ងៃមួយណា នាងរៀបក្រយា សំណុំវេចខ្ចី
ទឹកមួយបំពង់ នាងផ្ដល់ឱ្យប្ដី ពុនរែករត់ខ្មី
សព្វៗវេលា ។

ដើមឡើយរត់ហាត់ ដង្ហើមផុតៗ ស្ទើរដាច់ខ្យល់ណា
រត់វិលមកវិញ ប្រាប់ប្រពន្ធថា វាហត់ក្ដាត់ណា
ដូចនឹងស្លាប់ហោង ។

លុះដល់ពីរថ្ងៃ ទើបរត់ទៀតវៃ ដោយចិត្តបំណង
នឹងចង់ឱ្យបាន ដូចក្ដីប៉ុនប៉ង ប្រាថ្នានោះហោង
ចិត្តចង់សង្វាត ។

រត់ទៀតដល់ទី ដើមកាលេរតន្ទី ដោយចិត្តខ្ទីឃ្មាត
ត្បិតប្រពន្ធថា ចង់ចាំពុំឃ្លាត ខែងខំសង្វាត
ដូចក្តីប្រាថ្នា ។

លុះប្តីនាងរត់ រត់រួចពុំហត់ ដោយចិត្តសោះសា
ឯនាងនារី យល់ប្តីអាត្មា បរិបូណ៌ហើយណា
ទើបនាងឆាប់ក្រៃ ។

ទៅថ្កានមន្ត្រី ឱ្យគេថ្វាយប្តី ជាខ្ញុំក្សត្រថ្លៃ
មន្ត្រីនាំថ្វាយ ដូចចិត្តនាងវៃ បម្រើសព្វថ្ងៃ
ជាខ្ញុំរាជា ។

## បទតុះជន្តលីលា

និងថ្លែងសម្តែងចរចា ឯមហាក្សត្រា ព្រហ្មទត្តធិបតី ។
សម័យមួយថ្ងៃចក្រី ឱ្យប្រាប់សេនីយ សេនាពលផង ។
ត្បិតក្សត្រព្រហ្មទត្តជាច្បង មានព្រះបំណង ប្រពាតព្រឹក្សា ។
ឱ្យរៀបប្រុងប្រៀបបណ្ណា ការកបយសា ធិរាជស្តេចស្តែង ។
ភ្នាក់ងារខ្មាន់ការតាក់តែង រៀបគ្រប់ដំណែង ដំណើរក្សត្រា ។
ឯចៅនោះនៅគ្រឹហា ប្រាយប្រាប់ភរិយា នាងអើយឥឡូវ ។
ព្រះបាទនរនាថឥតគូ ស្តេចតែងពលព្យូហ៍ ប្រពាតព្រឹក្សា ។
ចូរចៅប្អូនពៅពុំងា ប្រដាប់ប្រដា ឱ្យបងឆាប់ថ្វាត់ ។
និងទៅហែចៅចក្រវត្តិ ព្រះបាទព្រហ្មទត្ត ឥស្សូរសិរសា ។
នាងស្តាប់សារសព្ទប្តីថា នាងរៀបក្រយា ឱ្យប្តីស្នេហ៍ស្នាល ។
អង្គរសោតល្អត្រកាល អប់ផ្កាត្រអាល ប្រហើរឈ្ងុយឈ្ងប់



អាហារត្រកាលសាយសព្វ រណ្តាប់គ្រាន់គ្រប់ ឱ្យប្តីស្នេហា ។
រុំជាសំណុំហើយណា ផ្ទង់ជាក្រយា ស្ងោយមហាក្សត្រថ្លៃ ។
នាងដឹងដំណឹងនោះវៃ ថាក្សត្រទៅព្រៃ និងព្រាត់គ្នាគ្នី ។
និងឃ្លាតអមាត្យមន្ត្រី មានប៉ុន្តែប្តី នាងនឹងពុនទៅ ។
ឯមហាក្សត្រចមចៅ ព្រឹកព្រាងច្រាលឆ្អៅ ប្រដាប់ព្រះអង្គ ។
ទ្រង់គ្រឿងរុងរឿងបញ្ចង់ ព្រះពស្ត្រទិព្វទ្រង់ ប៉ាក់ឆ្វាក់មាលា ។
ទ្រង់ស្រេចសម្តេចរាជា ស្តែងស្តេចយាត្រា ឡើងលើអស្សតរ ។
ចេញទៅដល់ក្រៅនគរ ព្រះអង្គបើកបរ រង្គរាជអស្សពាហ៍ ។
ក្តំក្តស់ខ្ពង់ខ្ពស់សោភា ឆ័ត្ររួចជួរចា មរមាសរៀបរាយ ។
អភិរម្យត្រសុំត្រសាយ ត្រសែតរំភាយ រំភើយសក់សែង ។
សេនាយោធាខះខែង ករកាន់លំពែង ហែៗច្រូងច្រាង ។
ដាវខែលក្រាស់ក្រៃលសងខាង សេនាកាន់កាង ទូនទាំងចាមរី ។
មហាក្សត្រព្រហ្មទត្តចក្រី ឯកឯងពិសី ពាលពេញពលា ។
ដល់ក្នុងកំឡុងព្រឹក្សា ស្តេចបរអស្សពាហ៍ លឿនលន់កន្លង ។
សេនាយោធាពលផង ខែងខំក្តាត់ហោង ពុំទាន់ក្សត្រា ។
ដិតដោយតាមក្រោយអស្សពាហ៍ ប៉ុន្តែចៅមា ណាពនោះឯងហោង ។
ត្បិតគាត់រត់ស្ទាត់កន្លង ទាន់ក្សត្រច្បាស់ច្បង ចមចក្ររាជា ។

## បទភាគគតិ

ព្រះបាទក្សត្រថ្លៃ ដល់ដើមព្រះជ្រៃ បញ្ឈប់អស្សពាហ៍
ព្រាត់មុខមន្ត្រី សេនីយសេនា យល់តែថៅមា
ណាពនោះឯងហោង ។

ទើបក្សត្រចមថៅ ឈប់រង់យូរទៅ ពុំយល់មនុស្សផង
ស្តេចឃ្លានក្រយា ស្ងោយមហាក្សត្រហោង ត្រមោចកន្លង
តែនឹងមាណវា ។

ទើបព្រះព្រហ្មទត្ត ធិរាជចមក្សត្រ លើសលើលោកា
សន្មតនាមនៃ មាណពនោះណា ឱ្យហៅថៅមា
យើងយសពណ្ណរាយ ។

ស្តេចសព្វហឫទ័យ ក្រសាលនៅនៃ កំឡុងព្រៃនាយ
ស្តេចលីលាលេង ព្រឹក្សាពណ្ណរាយ សាន្តសុខសប្បាយ
ទតព្រៃព្រឹក្សា ។

ស្តេចត្រាច់ក្នុងព្រៃ ឥតអ្នកណានៃ នឹងទាន់ក្សត្រា
សឹងរកក្សត្រថ្លៃ សព្វព្រៃព្រឹក្សា ខ្លាចខ្លួនក្តាត់ណា
រកមិនឃើញឡើយ ។

រីឯព្រះបាទ ព្រហ្មទត្តនរនាថ លីលាឡើងហើយ
បន្ទូលនឹងមា យើងថាថៅអើយ ថ្ងៃពន់ពេកហើយ
អង្គអញឃ្លានបាយ ។

ទន្ទឹងអស់គ្នា មន្ត្រីយោធា ចតុរង្គទាំងឡាយ
សឹងតែពុំយល់ រេហ៍ពលព្រាតព្រាយ បែកផ្លូវខ្វាត់ខ្វាយ
អស់ពុំយល់ណា ។



មាយើងទូលទៅ បពិត្រចមថៅ លើសលើលោកា
បាយអញខ្ញុំមាន គឺមោះខ្ទិះខ្នា ពុំគួរក្សត្រា
ធិរាជសោយសល់ ។

ស្តេចស្តាប់ហើយណា ថាយកមកវ៉ា កុំគិតសល់រំលល់
ទោះល្អមិនល្អ ខ្មៅសតាមកល អញឃ្លានណាស់សល់
អត់ឯណាបាន ។

ទឹកតើញាំងថៅ បានសំថៃនៅ ឬមួយពុំបាន
មាយើងទូលទៅ បពិត្រក្សត្រក្សាន្ត រីទឹកសោតមាន
គឺមោះតែថា ។

ដាក់នឹងបំពង់ ពុំគួរព្រះអង្គ ស្តេចសោយឡើយណា
ស្តេចស្តាប់ថាទៅ យើថៅកុំថា ចោះថៅម្ទឹម្ទា
យកមកឆាប់ៗ ។

ក្សិណថៅមាយើង ម្ទឹម្ទាដោះឡើង ទៅយកប្រដាប់
ដាក់ទឹកបំពង់ សំណុំបាយស្រាប់ ស្រេចស្រាយផ្លូវផ្តាប់
ថ្វាយមហាក្សត្រា ។

ស្តេចសោយអាហារ មាយើងត្រកាល មានរសពិសា
បាយបរិសុទ្ធស អង្ករនោះណា ដូចព្រះក្រយា
ស្តេចសោយប្រក្រតី ។

អាហារពិសា គាប់ព្រះឱស្ឋមហា ក្សត្រក្សាន្តចក្រី
បន្ទូលសរសើរ ថានេះមែនស្រី ប្រដាប់ចំណី
ពិសេសពិសា ។

ប្រពន្ធមាយើង ចេះរៀបថ្កុលថ្កើង មុខចៅមែនណា
ចៅអើយអាហារ ត្រកាលពិសា សឹងជាតិឱជា
រសត្រកាលក្រៃ ។

ជូនលើគម្លាន ឯណាមកមាន អាហារក្នុងព្រៃ
និងថាត្បិតឃ្លាន គួរពិសាក្រៃ មិនធ្លោះឡើយនៃ
ចំណីនេះជា ។

មាយើងបង្គំ មហាក្សត្រឧត្តម ឥស្សូរសិរសា
លុះស្ដេចសោយសល់ ស្គាល់មហាក្សត្រា ស្ដេចសោយគង្គា
បំពង់នោះនៃ ។

ទឹកសោតពិសា អប់អស់ក្លិនផ្កា ពិដោរប្រពៃ
ស្ដេចថាទឹកចៅ រសពិសាក្រៃ ឱនាងគាប់ចៃ
ចេះរៀបឱ្យប្ដី ។

មាយើងនោះណា បង្គំក្សត្រា លើកដៃលមកឆី
ឆីរួចស្កប់ស្កល់ បរិបូណ៌អស់ក្ដី ទើបព្រះចក្រី
បន្ទូលទៅថា ។

ចៅមាយើងអើយ អញហូបបាយហើយ មិនចេះអត់ស្លា
ចៅឱ្យថង់ចៅ មកឯអាយ៉ា អញនឹងស៊ីស្លា
ឥឡូវនេះនៃ ។

ចៅមាយើងថ្វាយ ក្សត្រថ្លៃពណ្ណរាយ ដោយព្រះហឫទ័យ
ស្ដេចសោយស្លាចៅ មាយើងនោះនៃ មានសព្វគ្រប់ក្រៃ
ឥតខ្វះឡើយណា ។



ទាំងទេពទារូ ក្រវាញក្លាំពូ ស្លាខ្ចីសោតណា
ក្រមួនមាត់ផ្ទង់ ព្រះអង្គសោយស្លា ហើយទើបត្រាស់ថា
ស្លាចៅនេះនៃ ។

សព្វគ្រប់មានមិញ ដូចកលស្លាអញ តែងឆីសព្វថ្ងៃ
ភ័ព្វអញឯងហើយ ចៅអើយគាប់ចៃ អញបានអាស្រ័យ
ចៅសព្វគ្រប់ហោង ។

បើអញបានដល់ ទីឋានមណ្ឌល ឯនាយហើយហោង
អញឱ្យយសចៅ ជាធំកន្លង ចៅកំសត់ផង
អញអាសូរចៅ ។

បន្ទូលម្លោះហើយ ក្សត្រាត្រាណត្រើយ ព្រះផ្ទុំលើភ្លៅ
មាយើងហើយថា ចៅអើយនែចៅ ស្ដាប់អញនឹងនៅ
និយាយមួយហោង ។

ស្ដាប់ណាចៅអាយ ដំណើរនិយាយ ព្រេងព្រឹទ្ធកន្លង
អញនៅថ្លាថ្លែង សំដែងទំនង និទានមួយហោង
ពីព្រេងអតីតា ។

ពុំទាន់និយាយ ដំណើរអភិប្រាយ សណ្ដាប់ដល់មា
យើងស្ដេចផ្ទុំលក់ សាន្តសុខមហិមា ក្រោមដើមនៃមហា
និគ្រោធនោះនៃ ។

រីកាលនោះណា មែនមានទេវតា រក្សាព្រះព្រៃ
ឮព្រះព្រហ្មទត្ត មហាក្សត្រជៀស្ឋជ័យ ស្ដេចបន្ទូលវៃ
នឹងមាយើងថា ។

ស្ដេចនឹងនិយាយ ទេពតាទាំងឡាយ បបួលគ្នីគ្នា
មកមីរលើជ្រៃ ស្ដាប់ស័ព្ទក្សត្រា យល់ស្ដេចនិទ្រា
ពុំបន្ទូលទៅ ។

ទេពតាខឹងក្តាត់ និងព្រះព្រហ្មទត្ត ធិរាជចមចៅ
ថាក្សត្រនេះណា មុសាក្រៃក្រៅ ពោលពាក្យអាសៅ
ពុំកាន់ពាក្យសត្យ ។

ថ្មោះយើងអត់ថ្វី ស្តេចពាលអប្រិយ កាច់មែកជ្រៃថ្វាត់
ទម្លាក់ទៅលើ សង្កត់មហាក្សត្រ ឱ្យស្តេចបង់បាត់
ព្រះជន្មជីវី ។

ថាបើពុំទាន់ នៅនេះក្រៃងខាន ស្តេចទៅបុរី
យើងកាច់ខ្លោងទ្វារ សង្កត់ចក្រី ព្រហ្មទត្តក្សិ៍យ
ឱ្យក្ស័យជន្មា ។

ថាបើបានទៅ លុះស្តេចចូលទៅ ដល់លើក្រឡា
បន្ទំរម្យរត័ន៍ តែស្ងាត់និទ្រា យើងប្រែក្រឡា
ជាពស់ទៅខាំ ។

ស្អប់ស្តេចកុហក ថាហើយដេកលក់ ឱ្យតែយើងចាំ
មាយើងងងុយ អង្គុយតែចាំ ឮពាក្យង៉ាំៗ
ង៉ាំៗនោះណា ។

មាយើងដាស់ស្តេច ឆាប់មួយរំពេច ទើបទូលទៅថា
បពិត្រស្តេចឡើង ជវ៉នអស្វា ឆាប់ៗម្ចីម្នា
ឥឡូវនេះនៃ ។

ត្បិតមានទេវតា និត្យនៅរក្សា លើដើមព្រះជ្រៃ
ខឹងថាស្តេចនិង និយាយហើយនៃ ផ្ទុំលក់រឹងរៃ
ស្ងៀមស្ងាត់ភាសា ។

ខ្ញុំចាំស្តេចផ្ទុំ រលីវទៅខ្ញុំ ឮពាក្យទេពតា
ស្តេចស្តាប់មាយើង ស្ទុះឡើងអស្សពាហ៍ បំផាយម្ចីម្នា
មាយើងដោយដិត ។



ក្សិណមែកព្រះជ្រៃ ធ្លាក់ផុតក្សត្រថ្លៃ ព្រះបាទព្រហ្មទត្ត
ស្តេចនៅរម្លង ពីភ័យមរណ៍ថ្វាត់ ទើបមាយើងគិត
ទូលទៅទៀតថា ។

បពិត្រពះភូ ធរារាជឥស្វរ នេះឯងមួយគ្រា
មួយទៀតខ្ញុំឮ ពាក្យអស់ទេពតា ថាដល់សីមា
ព្រះអង្គនាយនោះ ។

នឹងកាច់ខ្លោងទ្វារ សង្កត់ភូបាល រឹងរិញទៀតស្មោះ
ថាបើកន្លង រម្លងពីនោះ លុះព្រះអង្គឆ្ពោះ
ចូលក្នុងបន្ទំ ។

នឹងប្រែកាឡា ជាពស់មហិមា ខាំក្សត្រឧត្តម
បពិត្រក្សត្រា ទេពតាជំនុំ ដូច្នោះនេះខ្ញុំ
ឮជាក់ជាម្តង ។

## បទពំនោល

មហាក្សត្រព្រហ្មទត្តច្បាស់ច្បង ស្តេចស្តាប់ទំនង ទំនួលនៃចៅមាយើង ។
ទើបមហាក្សត្រាថ្កល់ថ្កើង ថាច្នោះមាយើង ប្រយ័ត្ននូវខ្លោងទ្វារនោះ ។ចៅ
កាន់រំពាត់វាត់គោះ ចៀសជួយតឿនស្មោះ ឱ្យរួចពីភ័យទ្វារធំ ។
ស្តេចមានហឫទ័យបារម្ភ បរសេះវែងខំ លុះទៀបនៃខ្លោងទ្វារនោះ ។
ក្សត្រថ្កើងមាយើងវាត់គោះ សេះសោតលោតឆ្ពោះ ច្រៀវច្រូចគ្រលួចមហិមា ។
បាក់ខ្លោងទ្វាររាជសីមា ផុតមហាក្សត្រា ក៏រួចរម្លងពីក្ស័យ ។
លុះដល់មណ្ឌលទិព្វថ្លៃ ចៅមាយើងវៃ ក្រាបលាទៅថ្កានគ្រឹះឋាន ។
ព្រះបាទព្រហ្មទត្តទ្រង់មាន បន្ទូលផ្តាំថ្កាន ថាចូរចៅទៅហោងណ៎ា ។
ហើយចៅវិលវិញយាត្រា មកឆាប់ម្ចីម្នា ចៅចាំដូចចៅឮហោង ។

មាយើងក្រួញក្រាបទូលស្នង បពិត្រនេះម្តង កុំព្រួយព្រះរាជហឫទ័យ ។
បានទៅនៅវិលវិងវៃ ចាំក្សត្រជៀស្នជ័យ ដ៏ជាមកុដសិរសា ។
ទូលស្រេចមាយើងម្ទីម្ទា មកផ្ទះអាត្មា ប្រាយប្រាប់ភរិយាអស់ក្តី ។
ដំណាលប្រាប់កាលចក្រី ព្រាត់មុខមន្ត្រី ទៅផ្តុំក្រោមដើមព្រឹក្សា ។
ប្រាប់ពីស្តេចសោយក្រយា សរសើរនាងថា ភរិយាបានចេះស្ងួនគ្រង ។
ប្រាប់អស់ដំណើរទំនង នាងត្រេកអរផង ត្បិតបានដូចចិត្តចិន្តា ។
មាយើងនោះនិងភរិយា ហូបបាយហើយណា ក៏កាន់ដាវឡើងទៅចាំ ។
អង្គុយជិតនៅគយឃ្លាំ ក្នុងចុងរោងរាំ ព្រះបាទសម្តេចព្រហ្មទត្ត ។
មន្ត្រីក្រាស់ក្រៃច្រើនក្តាត់ ប្រុងប្រាណប្រយ័ត្ន ដ៏ពេញនៅរាជរោងរម្យ ។
លុះដល់អធ្រាត្រដាស់ទំ ដេកស្ងាត់ជ្រងំ ពុំភ្ញាក់ដល់ម្នាក់ឡើយណា ។
កាលនោះឯងឯទេវតា ប្រាណប្រែកាឡា ជាតិជាពស់វាវទៅហោង ។
ទំហំពស់ធំកន្លង ប៉ុនដើមត្នោតផង ក៏លើកពពារគួរខ្លាច ។
មានភ្នែកនោះធំត្រដាច ចង្កូមសស្ងាច និងខាំព្រះមហាក្សត្រា ។
មាយើងដោះឡើងម្ទីម្ទា លើកខាន់មុតថ្លា ក៏វាត់ត្រូវសិរសាសល់ ។
ឈាមពស់ខ្ទាត់ខ្ទាយទៅដល់ ទេពីនិមល ក៏ពេញនាព្រះថនា ។
ទើបចៅមាយើងគិតថា ពស់នេះមរណា អសារសោះសូន្យជីវី ។
ឈាមដូចដល់ព្រះទេពី វរ័តនក្សត្រី ច្នេះតើនឹងធ្វើម្តេចបាន ។
ជ្រះឈាមពីនាងកល្យាណ និងដាស់ក្សត្រក្សាន្ត យល់ក្តីពុំគួរក្តាត់ណា ។
និងយកដៃជូតឱរ៉ា សោតសឹងពុំជា កើតក្តីពុំគួរពេកក្រៃ ។
ទើបយកខ្មោចពស់នោះវៃ ដាក់នៅក្រោមពូ ក្រឡាបន្ទំរម្យរ័តន៍ ។
ស្រេចហើយទើបគាត់ហាមាត់ លិទ្ធឈាមដែលជិត នៅនាព្រះស្តន់ក្សត្រី ។
នាងនាថភ្ញាក់ឥន្ទ្រិយ ទើបដាស់ភូមី ដ៏ជាគម្តែងក្រឡា ។
នាងឱ្យប្រាយប្រាប់ថាមា យើងយកជីវ្ហា មកលិទ្ធនូវដោះខ្ញុំហោង ។



ស្តេចស្តាប់ក្រោធក្រៃកន្លង ត្រាសប្រើពលផង ថាម្នាលពេជ្ឈឃាដម្ទីម្ទា ។
ចូរឆាប់ចាប់ចងយកវា កំណាចមហិមា នេះនាំយកទៅសម្លាប់ ។
ក្សិណនោះពេជ្ឈឃាដចូលចាប់ ចងមាយើងខ្ជាប់ ក៏នាំយកទៅម្ទីម្ទា ។
ហេតុស្តេចឥតពិចារណា ពុំគិតគុណមា យើងយកតែពាក្យទេវី ។
ពេជ្ឈឃាដនាំទាំងរាត្រី ទៅបូព៌ទិសទី ក៏ថានឹងអ្នកនាយទ្វារ ។
ឱ្យបើកត្បិតព្រះភូបាល មានព្រះឱង្ការ ឱ្យនាំអ្នកទោសទៅកាប់ ។
ក្សិណនោះនាយទ្វារស្តែងស្តាប់ យល់ខុសនឹងច្បាប់ សម្លាប់អ្នកទោសទាំងយប់ ។
ថាទោសនេះម្តេចអ្នកឈប់ ប្រាយប្រាប់សព្វគ្រប់ ដំណើរដំណាលសេចក្តី ។
នាំអ្នកទោសទាំងរាត្រី ពុំត្រូវច្បាប់ពី បុរាណគន្លងឡើយណា ។
ពេជ្ឈឃាដឆ្លាស់ឆ្លើយរឹងថា អញដឹងឯណា ជាទោសធ្ងន់ស្រាលអ្វីៗ ។
ស្តេចប្រើអញទាំងរាត្រី ចៅមករកក្តី លើព្រះបម្រើម្តេចបាន ។
អំណាចអ្វីៗឯងមាន ក៏អញនឹងហ៊ាន នាំគេមកសម្លាប់លេង ។
អម្បាលចៅមាយើងឯង ម្តេចពុំកោតក្រែង ក៏ទាស់ព្រះរាជអាជ្ញា ។
នាយទ្វារសោតឆ្លើយរឹងថា បើព្រះអាជ្ញា លុះត្រូវនឹងច្បាប់ទើបបាន ។
បើខុសនឹងច្បាប់បុរាណ យើងឃាត់ខាំងខាន បានត្បិតយើងជានាយទ្វារ ។
បើយើងក្រាបទូលនាកាល នោះព្រះភូបាល និងធ្វើម្តេចៗតាមកល ។

## បទកាកគតិ

នាយទ្វារនោះណា បង្ខានអាជ្ញា ឈរឈប់រចល់
ទើបនាំនិទាន មែនមានមនុស្សសល់ ប្រាយប្រាប់អស់កល
និងពេជ្ឈឃាដហោង ។

ចៅអើយនិយាយ កាលពីព្រេងនាយ ទុកជាទំនង
មុនមានស្រីម្នាក់ មានកូនមួយហោង ចិញ្ចឹមស្ការផង
ស្រឡាញ់រក្សា ។

ស្រីនោះទៅផ្សារ ទុកនៅតែស្ការ និងកូននោះណា
ផ្ដេកក្នុងអង្រឹង ទើបចរយាត្រា ក្រោយនោះពស់អា
សិរពិសយង់ឃ្នង ។

ក្បិណពស់លលាំ វារមកចឹកខាំ កូននោះមរណ៍ហោង
ស្ការយល់ពស់ពិស ទ្រស្ដទ្រឹស្ដកន្លង ស្ការប្រខាំផង
នឹងពស់នោះណា ។

កាលនោះពស់ពាល ប្រខាំនឹងស្ការ ស្ការខាំមរណា
ម្ចាស់មកពីផ្សារ ក្បិណស្ការនោះវា រត់ដោយមាតា
ទៅទទួលហោង ។

រីស្រីម្ចាស់ស្ការ យល់ឈាមរន្ទាល នៅខ្លួននោះផង
ប្រមាណគិតថា ស្ការកាចកន្លង ខាំកូនជាម្ដង
មិនឈាមអ្វីឡើយ ។

ខឹងឆុលឆៀបឆាប់ វាយស្ការសម្លាប់ បោះបង់សៀតហើយ
ចូលទៅមើលកូន ឃើញសូន្យឥតត្រើយ ពិតពុំទេឡើយ
យល់ពស់មរណា ។

ទើបគិតឯងយល់ ថាពស់កាចសល់ ខឹងខាំបុត្រា
ស្ការការបុត្រនោះ ប្រខាំសោះសា យល់ស្លាមជាក់ជា
បន្ទាល់ទៀងពិត ។

ទើបគិតស្ដាយស្ការ ស្ដាយកូនសង្សារ សោះសូន្យជីវិត
សោកឯងផ្សារឯង ស្ដាយអស់ពីចិត្ត អញខ្លាចមហាក្សត្រ
នឹងស្ដាយច្នោះហោង ។



ហេតុនេះអញពុំ បើកបើខឹងខំ ខុសច្បាប់កន្លង
ចៅទៅទ្វារទៀត រីអញនេះម្ដង មិនបើកឡើយហោង
និយាយសោតមាន ។

ពេជ្ឈឃាដស្ដាប់ហើយ ខំពុំបានឡើយ ទើបនាំទៅថ្កាន
នាយទ្វារទក្សិណ ឱ្យបើកត្បិតមាន ព្រះបន្ទូលថ្កាន
ប្រើយើងនេះណាំ ។

នាំមនុស្សទៅកាប់ ចោលបើកឆាប់ៗ ដូចព្រះអាជ្ញា
នាយទ្វារទក្សិណ នោះសោតឆ្លើយថា លោកដែលឯណា
នាំទាំងរាត្រី ។

ពេជ្ឈឃាដឆ្លើយថា ព្រះអើយអុញណា ប្រកែកថាអ្វី
បើកទៅឆាប់ៗ នឹងកាប់ម្នាម្នី នៅទាស់សេចក្ដី
លើព្រះអាជ្ញា ។

យើងនេះមិនព្រាង កុំចៅអួតអាង ឃាត់ខាំងរាំងរា
បើចៅមិនជឿ ទៅទូលក្សត្រា យើងពុំមុសា
វាទវៀចឡើយហោង ។

នាយទ្វារឆ្លើយថា ជឿជាក្សត្រា ប្រើជាក់មែនហោង
នាំទៅសម្លាប់ តែច្បាប់សព្វដង សម្លាប់មនុស្សផង
សឹងនាំទៅថ្ងៃ ។

នេះនាំទាំងយប់ យើងនឹងឱ្យឈប់ លុះស្រាងឧទ័យ
បើចៅនឹងខំ យើងពុំបើកវៃ ច្បាប់យើងទីទៃ
ចេះចាំស្មាត់នៅ ។

ហើយមាននិយាយ អំពីព្រេងនាយ អញនឹងប្រាប់ចៅ
ចៅស្តាប់អញថ្លែង សំដែងសំដៅ ដោយនិទានទៅ
ដំណើរអតីតា ។

មុនមានសេដ្ឋី មានទ្រព្យប្រាំបី កោដិឃ្លាំងនោះសា
ចិញ្ចឹមឆ្កែចាំ ឆ្កែប្រាំរយណា សឹងឆ្កែជាៗ
បានដូចនូវចិត្ត ។

ទោះមនុស្សជាចោរ ឃើញតែស្រមោល បណ្តេញដោយជិត
ព្រូសព្រមនឹងខាំ ប្រចាំគ្នាស្ងាត់ រក្សាសម្បត្តិ
នៃមហាសេដ្ឋី ។

សេដ្ឋីនោះណា សឹងឱ្យរក្សា ឆ្កែជាប្រក្រតី
មានខ្ញុំដណ្តាំ បាយឱ្យឆ្កែស៊ី សព្វទិនរាត្រី
ពុំសោះឡើយណា ។

មានកាលមួយថ្ងៃ ចោរប្រាំរយវៃ គប់គិតនឹងគ្នា
វាជីកឧមង្គ ឡើងលួចទ្រព្យមហា សេដ្ឋីនោះណា
អស់ពីឃ្លាំងហោង ។

ឆ្កែប្រាំរយយល់ ក្រជូរដេញដល់ ព្រមព្រូសខឹងខ្លាំង
ដេញក្នុងឧមង្គ ក្នុងឋានកំបាំង ខាំចោរស្លាប់ទាំង
ប្រាំរយអស់វៃ ។

លុះព្រឹកសេដ្ឋី យល់ទ្រព្យបាត់ពី មណ្ឌលឃ្លាំងជ័យ
ប្រាំមួយកោដិគត់ អស់ឥតសង្ស័យ សេដ្ឋីក្រោធក្រៃ
ថាអះអសារ ។

ចិញ្ចឹមឆ្កែថ្វី ឱ្យបាយវាស៊ី វាដេកឥតការ
ចោរលួចទ្រព្យអស់ ឆ្កែពេញទាំងវាល ឥតសព្វឥតសារ
នឹងទុកថ្វីវា ។



សេដ្ឋីឱ្យចាប់ ឆ្កែទៅសម្លាប់ ឥតសំណល់ណា
លង់លុះខ្មោចចោរ ធុំក្លិនដល់មហា សេដ្ឋីនោះណា
ដ៏ជាម្ចាស់ទ្រព្យ ។

សេដ្ឋីថាយើ អស់ក្មេងនេះតើ យកឆ្កែទៅកាប់
ត្រង់ឋានឯណា វាស្អុយស្ទើរស្លាប់ ទៅយកនាប់ៗ
អូសចេញឱ្យឆ្ងាយ ។

ខ្ញុំមហាសេដ្ឋី ប្តឹងប្រាប់រឹងខ្មី ថាឆ្កែទាំងឡាយ
យើងខ្ញុំសម្លាប់ កណ្តាលព្រៃឆ្ងាយ មិនធុំដល់អាយ
នេះឡើយម្ចាស់ថ្លៃ ។

ទើបមហាសេដ្ឋី ថាច្មោះខ្មោចអ្វី ធុំស្អុយពេកក្រៃ
អារកហិតមើល ប្លែកក្រៃវិស័យ ខ្ញុំនោះវៃៗ
ហិតរកហោងណា ។

ដល់មាត់រណ្តៅ នោះធុំស្អុយក្រៅ វិស័យសោះសា
ខ្ញុំនោះវិលមក ប្រាប់សេដ្ឋីថា រណ្តៅមួយណា
ធុំស្អុយពេកសល់ ។

ទើបសេដ្ឋីថា បើច្មោះអស់គ្នា ទៅជីកឱ្យយល់
ក្សិណខ្ញុំសេដ្ឋី កាន់ចបរចល់ ជីកទៅយង់យល់
ខ្មោចចោរមរណា ។

របួសទៀងទេ សឹងចង្កូមឆ្កែ នោះគ្រប់អស់គ្នា
ទ្រព្យក្នុងឧមង្គ សឹងគង់នៅជា អស់ខ្ញុំនោះវា
មកប្រាប់សេដ្ឋី ។

សេដ្ឋីគន់គិត តែក្នុងគំនិត ដឹងដើមសេចក្តី
ថាអេះអញឆ្លោយ ឯងឱ្យសម្លាប់ ឆ្កែនោះពុំគាប់
ខុសទេហោងណា ។

ចៅអើយមហាក្សត្រ   ព្រះបាទព្រហ្មទត្ត   លើសលើលោកា
អញថានឹងផ្ដោយ   ស្ដាយក្រោយដូចមហា   សេដ្ឋីនោះណា
មិនលែងឡើយហោង ។

អញពុំបើកចៅ   ចៅនាំយកទៅ   ទ្វារឯទៀតផង
ទ្វារអញមានច្បាប់   ចេះស្រាប់កន្លង   អញពុំបើកហោង
កុំបង្ខំអញ ។

ពេជ្ឈឃាដនោះស្ដាប់   អស់អាថ៌សារសព្ទ   នោះទើបនាំចេញ
ទៅទ្វារបស្ចិម   កាលគ្រានោះវិញ   អ្នកទ្វារនោះមិញ
ពុំបើកឡើយហោង ។

ពេជ្ឈឃាដថាបើ   ចៅពុំបើកតើ   មានច្បាប់ទំនង
ដំណើរនោះម្ដេច   ចូរចៅសារសង   ប្រាយប្រាប់អញហោង
អស់អាថ៌សារសព្ទ ។

ទើបអ្នកទ្វារថា   លោកដែលឯណា   នាំមនុស្សទៅកាប់
ទាំងយប់រាត្រី   ខុសពីក្បួនច្បាប់   ចៅអើយចូរស្ដាប់
និយាយអញមាន ។

មុនមានមហាក្សត្រ   សោយរាជសម្បត្តិ   សម្បូរធនធាន
ចិញ្ចឹមសេកសត្វ   សេករ័តន៍កល្យាណ   ហើរទៅហិមពាន្ត
រកភ័ស្តុចំណី ។

សេកមានសម្បុរ   នោះល្អនិមល   កបបញ្ចិន្ទ្រីយ
កាលនោះស្ដេចយល់   សម្បុរបក្សី   សេកស្ងួតសោភី
ល្អល្អះប្រពៃ ។



ស្ដេចអរកន្លង   បន្ទូលទៅផង   សេកស្ងួតនោះវៃ
សេកអើយសម្បុរ   អ្នកយល់ល្អក្រៃ   ហេតុម្ដេចចូរលៃ
លកប្រាប់អញរ៉ា ។

សេកសោតទៀងទូល   បពិត្រឥស្សូរ   ជាមកុដសិរសា
សម្បុរខ្ញុំល្អ   ត្បិតខ្ញុំភោក្តា   ផ្លែស្វាយនៅនា
ព្រៃព្រះហិមពាន្ត ។

វិស្វាយនោះណា   បើចាស់ជរា   អាក្រក់ប៉ុន្មាន
បានបរិភោក្តា   ផលានោះក្សាន្ត   ក្សិណនោះប្រែប្រាណ
កម្លោះរឹងវៃ ។

ស្ដេចស្ដាប់សាសត្យ   សេកស្ងួតទូលថ្វាត់   បន្ទូលថាហៃ
សេកអើយបើច្នោះ   អ្នកទៅឆាប់វៃ   ពាំនាំពីព្រៃ
ផ្ញើយើងនឹងផង ។

សេកសោតទទួល   ព្រះបន្ទូលស្រួល   ស្រុះស្រេចអស់ក្ដី
ហើយហើរផ្លេកផ្លោះ   ទៅស្មោះឃ្មាតខ្មី   រកភ័ស្តុចំណី
ចំណង់ភោក្តា ។

លុះនឹងវិលថ្កាន   ទើបសេកពាំបាន   ស្វាយមួយនោះណា
មកផ្ញើមហាក្សត្រ   ស្ដេចអរក្តាត់ណា   ទទួលផល្លា
ពីបក្សីសត្វ ។

ស្ដេចគិតថាស្វាយ   នេះតិចអម្បាយ   បានពីរបីម៉ាត់
បើអញនឹងផង   ឱ្យល្អខ្លួនថ្វាត់   តែអញឯងក្សត្រ
នៅបុត្រភរិយា ។

និងញាតិទាំងឡាយ   បើច្នោះបេះស្វាយ   នេះទៅដាំន
ឋានមួយបើដល់   បានផលព្រឹក្សា   សីមយើងន៍
ផងឱ្យគ្រប់ហោង ។

និងមានរូបរ័តន៍ ប្រពៃល្អក្តាត់ ពេកពន់កន្លង
ទើបស្តេចបណ្តុះ ស្វាយនោះជាម្តង ដុះដូចស្តេចប៉ង
បំណងប្រាថ្នា ។

ស្តេចឱ្យទៅដាំ មានអ្នកផងចាំ ពិភ័ក្តិរក្សា
លុះស្វាយនោះធំ បានផលផ្លែផ្កា ហេតុដាំនោះណា
លើរន្ធនាគនៃ ។

ពិសនាគសព្វសាយ ជ្រួតជ្រាបផ្លែស្វាយ ពិសពស់វិស័យ
លុះស្វាយនោះធំ ទើបក្សត្រជៀស្ឋជ័យ ឱ្យបេះច្រើនក្រៃ
យកមកហោងណា ។

ស្តេចឱ្យអមាត្យ ជំនិតព្រះបាទ នឹមុនក្សត្រា
អមាត្យនោះនឹ ពុលពិសមរណា នៅព្រះភក្រ្តមហា
ក្សត្រក្សាន្តនោះវៃ ។

ស្តេចយល់អមាត្យ ពុលពិសសល់ខ្វាត ទ្រង់ព្រះក្រោធក្រៃ
ពុំពិចារណា ឡើយមហាក្សត្រថ្លៃ ថាសេកចង្រៃ
នឹងសម្លាប់អញ ។

ភ័ព្វអញនេះម្តង អញឱ្យនឹលង មើលមុនមែនមិញ
បើអញនឹងឯង ឥតក្រែងសមអញ អស់ជីវិតវិញ
មិនលែងឡើយណា ។

ស្តេចខ្វាល់ផុរឆាប់ វាយសេកសម្លាប់ ឥតពិចារណា
តំណពីនោះ ស្វាយនោះផ្លែផ្កា ឥតនរអ្នកណា
នឹងហ៊ានបេះនឹ ។



លុះចំណេរទៅ នាគនោះនិត្យនៅ ពុំបានថយពី
លំនៅនោះចេញ ពិសពេញធរណី ប្រែជាសាបឱ្ហី
ពុំពុលឡើយណា ។

អង្វែងទៅណាស់ តាចាស់ដូនចាស់ ពិបាករក្សា
ដរីមហាក្សត្រ មកគិតគ្នាថា យើងនេះជរា
ចាស់ណាស់ទៅហើយ ។

ទន្ទឹងតែស្លាប់ វាមិនឆាប់ស្លាប់ ដូចចិត្តសោះឡើយ
បើច្មោះយើងរស់ ជាមនុស្សថ្វីអើយ ពិបាកឥតត្រើយ
មកយើងទៅនឹ ។

ស្វាយដែលស្តេចដាំ ឱ្យស្លាប់ទៅចាំ រស់រូបធ្វើអ្វី
ពិបាកអាត្មា រក្សាដរី គាត់គិតព្រមប្តី
ប្រពន្ធហើយទៅ ។

បេះបានមកនឹ ក្សិណនោះឯប្តី ប្រែសក់ជាខ្មៅ
សម្បុរជាក្លោះ(១) ឥតខ្ទោះហ្មងសៅ ក្រឡេកមើលទៅ
ប្រពន្ធនោះណា ។

ប្រែជាក្រមុំ សម្បុរគួរសម ដោះដូចបទុមា
ប្តីថានាងល្អ នាងមកពីណា ប្រពន្ធឆ្លើយថា
យើប្លែកអញហើយ ។

ប្តីព្ធភរិយា ចាំតែពាក្យថា មុខមិនស្គាល់ឡើយ
ទើបឆ្លើយទៅថា ឱលាបអញអើយ ពាក្យប្រហែលហើយ
រូបរាងទីទៃ ។

---

(១) ពាក្យបុរាណគឺកម្លោះ

ប្រពន្ធឆ្លើយថា ព្រះអើយអញណា ខ្លារង្វេងព្រៃ
ក្រពើរង្វេង បឹងឯងសព្វថ្ងៃ នរណាឡើយនៃ
អញឯងជូនចាស់ ។

ចៅឯងសក់ស ខ្នងកោងមិនល្អ ឥឡូវប្រែផ្លាស់
ជាសក់ខ្មៅញាប់ ចំណាប់ធំណាស់ មុនមិញសោតចាស់
ឥឡូវកម្លោះ ។

ប្ដីថាយីអើ ឱ្យស្លាប់មិញតើ មកនីស្វាយនោះ
ម្ដេចអញនិងមេ ប្រែខ្វៃជាក្លោះ មេអើយបើច្នោះ
ជាភ័ព្វយើងឯង ។

ជូនតាប្រែប្រាណ ស្រេចវិលវិងថ្កាន លំនៅឥតក្រែង
រក្សាដីរ៍ ដូចពីមុនព្រេង ដោយជាអញឯង
ពិតពុំឃ្លាតឃ្លា ។

កាលនោះស្ដេចយល់ កម្លោះនិមល រូបរាងសោភា
ស្ដេចត្រាស់ដណ្ដឹង ថាមនុស្សពីណា មកនៅរក្សា
ដីរ៍អញហោង ។

ទើបតាកម្លោះ ទូលទៅតាមស្មោះ បពិត្រច្បាស់ច្បង
ខ្ញុំគឺតាចាស់ នៅនេះឯងហោង ត្បិតនីស្វាយផង
ប្រែប្រាណច្នេះណ៎ា ។

ស្ដេចស្ដាប់ថាយើ ស្វាយពុលមិញតើ ម្ដេចប្រែជាៗ
ច្នេះចូរអ្នកផង ទៅបេះមីម្នា យកមកឆាប់រ៉ា
អញនឹងឱ្យនី ។

អាមាត្យក្រាបលា ទៅបេះផល្លា មកថ្វាយភូមិ
ទើបស្ដេចឱ្យអា មាត្យមុខមន្ត្រី នីមុនចក្រី
ចង់ដឹងអក្ខរា ។



អាមាត្យ ១នី ល្អអស់ឥន្ទ្រិយ ប្រពៃសោភា
ស្ដេចយល់ច្នោះវៃ ព្រះទ័យសង្កា ត្រាស់ប្រើឱ្យមហា
អាមាត្យមួយនីទៀត ។

វែងល្អនិមល ស្ងួតិសមសម្បុរ ឡើងដូចរមៀត
ស្ដេចត្រាស់ឱ្យអា មាត្យមួយនីទៀត ទើបស្ដេចបានបៀត
ទ្រង់និងព្រះហស្ត ។

ឯងឱ្យបុត្រី បុត្រាមហេសី ទ្រង់សោយទាំងអស់
សឹងមានព្រះអង្គ នោះប្រែប្រាណផ្លាស់ ចាកចោលឯចាស់
ក្រឡុះជាពាល(១) ។

ស្ដេចយល់ច្នោះហើយ ទើបក្សត្រត្រាណត្រើយ សោយផលអាហារ
ល្អអស់ព្រះអង្គ រុងរឿងត្រកាល សម្ដេចភូបាល
ប្លែកនឹងសព្វគ្រា ។

ទើបក្សត្រជៀស្ដជ័យ គិតក្នុងព្រះទ័យ អង្គីក្ដីណា
ហេតុអ្វីស្វាយពុល បានប្រែជាៗ ស្ដេចត្រាស់ឱ្យអា
មាត្យមើលអស់ក្ដី ។

អាមាត្យទៅមើល រណ្ដៅនោះឃើញ នាគនៅអំពី
មុនមានដូច្នោះ ទើបទូលចក្រី ស្ដេចមានព្រះពី
ចារណាយង់យល់ ។

ជាពស់នាគា ជ្រួតជ្រាបព្រឹក្សា ពិសពស់អស់កល
ពីមុននាគមិញ ពិសពេញសព្វសល់ អញឯងដាលដល់
សម្លាប់សេកសត្វ ។

---

(១) ក្មេង

ស្តេចសែននឹកស្តាយ សេកសួគ៌ពណ្ណរាយ អសារបង់បាត់
នែចៅពេជ្ឈឃាដ ព្រះបាទព្រហ្មទត្ត អញខ្លាចមហាក្សត្រ
នឹកស្តាយក្រោយក្រៃ ។

ហេតុថ្មោះឯងអញ ពុំបើកចៅចេញ ទៅទាំងយប់វេរ
បើទោសខ្លាំងសល់ ចៅចាំដល់ថ្ងៃ ច្បាប់មានក្សត្រថ្លៃ
នឹងខ្វាល់ពុំបាន ។

ពេជ្ឈឃាដស្តាប់ស្តែង នាយទ្វារសំដែង ដំណាលនិទាន
ទើបទៅឯទ្វារ ឧត្តរទីឋាន ពេជ្ឈឃាដហៅហាន
ស្រែកប្រាប់ទៅថា ។

វ៉ឺយអស់នាយទ្វារ រក្សាសព្វកាល បើកអញម្នីម្នា
ត្រាស់ប្រើអញនាំ អ្នកទោសនេះណា ទៅកាប់សោះសា
ចៅបើកអញឆាប់ ។

នាយទ្វារឆ្លើយទៅ ថាចៅវ៉ឺយចៅ មិនដែលមានច្បាប់
នាំអ្នកទោសទៅ ទាំងយប់សម្លាប់ អញយល់ពុំគាប់
ខុសព្រះមាត្រា ។

ពេជ្ឈឃាដខឹងខំ ថាម្តេចក៏ពុំ បើកព្រះអាជ្ញា
ឃាត់អញអើភាន ឯងមានច្បាប់ណា ឱ្យឯងរាំងរា
លើព្រះបម្រើ ។

នាយទ្វារឆ្លើយទៅ ថាពេជ្ឈឃាដចៅ ងារអញឯងបើ
អញឃាត់ម្លេះខុស ច្បាស់ដូច្នោះតើ ចៅនឹងខំប្រើ
ឱ្យបើកទៅបាន ។

អញជានាយទ្វារ ពីមេពីបា រៀងពីបុរាណ
មិនដែលឮថា ដូច្នោះនឹងមាន បើទោសប៉ុន្មាន
ក្សត្រមានបុណ្យថ្កើង ។



ប្រើនាំទៅផ្តង ចៅនៅនេះហោង ទំរាំព្រឹកឡើង
សឹមនាំចេញថ្វាត់ យើងឃាត់តាមរឿង បើត្លងទោសយើង
សឹងមានគ្រប់គ្នា ។

យល់តែស្តេចប្រើ យើងបើកហើយតើ មិនខុសមាត្រា
ដំណានិងឃ្លៀង លំអៀងច្បាប់ប្រា កងកើតអនា
ទា[១] ផ្ទៃក្រោម[២] ក្រៃ ។

ស្រដីរាជការ ដោយមុខភ្ញាក់ងារ កាន់ខ្ជាប់ទីទៃ
យល់តែអំណាច ល្មមខ្លាចៗក្រៃ បើពុំល្មមនៃ
ទាស់សិនដោយច្បាប់ ។

មុខមន្ត្រីធំ បើបានជំនុំ ព្រមប្រើសម្លាប់
ឮតែក្សត្រា ពុះពារប្រើកាប់ ក្រោធក្រៃផុរឆាប់
និងព្រះអំណាច ។

ចៅអើយច្បាប់មាន ក្សត្រពីបុរាណ បរមរៀងរាជ
បើពុំទ្រង់ធម៌ សម្មាឯងអាច អាងព្រះអំណាច
ខុសច្បាប់ហើយណាំ ។

មុខមន្ត្រីធំ អ្នកប្រាជ្ញជំនុំ គិតព្រមគ្នីគ្នា
បណ្តេញស្តេចបង់ ពីក្នុងនគរា ត្បិតស្តេចពុះពារ
បំពាក់បំពាន ។

បើរាស្ត្រមន្ត្រី ពុំដោយច្បាប់ពី បរមបុរាណ
ល្មមលក់ល្មមព្នៃ ល្មមឱ្យក្ស័យបាន ចៅខំប៉ុន្មាន
អញពុំបើកឡើយ ។

(១) ការមិនអើពើ
(២) ផែនដី

## បទព្រហ្មគីតិ

កាលនោះឯមហាក្សត្រ ព្រហ្មទត្តតើនឡើងហើយ
ហប្ញទ័យសោតពុំស្បើយ គិតទៅដល់មាយើងថា ។
មាយើងមានគុណក្រៃ កាលនៅព្រៃមានតែមា
យើងឯងឥតនរណា ក្រៅអំពីមាយើងឡើយ ។
ឥឡូវនេះអញប្រើ ឱ្យគេធ្វើគុតគាត់ហើយ
គេកាប់ឬនៅឡើយ អះអញស្តាយពេកណាស់ណា ។
ស្តេចត្រាស់ឱ្យអាមាត្យ រត់ខ្មីឃ្មាតរួសម្ទីម្ទា
ទៅតាមយកចៅមា យើងមកវិញកុំពិឃាត ។
កាលនោះអមច្ចា គ្រួញក្រាបលារត់សង្វាត
តាមទាន់ពេជ្ឈឃាដ នៅនាទ្វារឧត្តរនោះ ។
ទើបនាំមាយើងមក វិលវិងមកថ្វាយក្សត្រស្មោះ
ទើបស្តេចបន្ទូលឆ្ពោះ ដណ្តឹងចៅមាយើងថា ។
ហៃមាយើងអើយចៅ កាលអញទៅលេងព្រឹក្សា
អញយល់មាឯងជា មានគំនិតគំនួរក្រៃ ។
ឥឡូវម្តេចចៅគិត ប្រាណប្រែចិត្តទៅទីទៃ
ចូរចៅចែងសម័យ ចរចាមកឥឡូវវ៉ា ។
មាយើងទូលពិនិត្យ ថាបពិត្រព្រះរាជា
ក្នុងកាលយប់មិញណា ពស់វាមកខាំក្សត្រថ្លៃ ។
ខ្ញុំកាប់ពស់អន្តរាយ លោហិតខ្ចាយពីក្រោមក្រៃ
ពេញព្រះថនានៃ វរទេវីពិសេសសល់ ។
ខ្ញុំពុំហ៊ានប្រមាថ ដាស់ព្រះបាទឱ្យអំពល់
នឹងយកដៃជិតដល់ សោតពុំគួរទើបខ្ញុំខំ ។



យកអណ្តាតលិទ្ធ ឈាមកូវកើតក្វាមពិតពុំសម
ជ្រាបដល់ព្រះអង្គ អម្ចាស់ឱ្យចងយកទៅកាប់ ។
ខ្ញុំនឹងទូលក្សត្រក្សាន្ត ទាស់ពុំហ៊ានក្រែងខុសគាប់
អំពល់បើនឹងស្លាប់ តាមវេរាអំពើកម្ម ។
តេជះហេតុអំពើ ត្រង់ពុំធ្វើវេរាកម្ម
ទើបខានដោយសារឆ្នាំ ទ្វារជំទាស់ពុំឱ្យទៅ ។
បើពុំពិចារណា គឺអសារសោះសូន្យសៅ
ក្សិណក្ស័យជីវិតនៅ នាធរណីនាយឥតការ ។
ស្តេចស្តាប់ដណ្តឹងឆ្ពោះ ថាបើច្នោះខ្មោចពស់ពាល
ចៅទុកឯណាកាល ឥឡូវចៅប្រាប់អញហោង ។
មាយើងទូលទៅថា ខ្ញុំទុកជាបន្ទាល់ផង
ទាំង ៣ កំណាត់ហោង ក្រោមមន្ទីរទិព្វភូបាល ។
ទើបស្តេចឱ្យទៅយក ខ្មោចពស់មកមែនដូចសារ
សព្វចៅមាយើងកាល នោះព្រះអង្គជឿជាក់ស្តែង ។
ក្សត្រថ្លៃបុណ្យខ្ពង់ខ្ពស់ យល់ខ្មោចពស់ទ្រង់ស្ញប់ស្ញែង
ព្រឺព្រួចប្រឹងគ្រញែង ព្រះសិរសីបន្ទូលថា ។
ភ័ព្វជាមាយើងអើយ កុំអីឡើយលុះមរណា
ឱមាយើងនេះមហា គុណអនេកអនន្តក្រៃ ។
អ្នកផងសឹងស្ញប់ស្ញែង ព្រឺគ្រញែងខ្លួនទីទៃ
យល់គុណមាយើងក្រៃ ក្រាស់ឥតនឹងថ្លឹងថ្លាថ្លែង ។
ស្តេចឱ្យស្រាយចំណង មាយើងហោងប្រោសលះលែង
ទោសទុក្ខបង់រវែង ហើយបន្ទូលដោះសាថា ។
ចៅអើយហេតុអញខ្លៅ ធ្វើទោសចៅឥតករុណា
កុំចៅយកទោសា អញទទួលថាខុសហើយ ។

ទើបស្ដេចគិតគុណក្រៃ ឱ្យយសថ្លៃឥតស្មើឡើយ
ដល់មាយើងជាត្រើយ ជាមន្ត្រីធំកន្លង ។

នរអ្នកសិងចុះឡើង ថៅមាយើងឥតថ្មីមផង
ហេតុបានភរិយាត្រង់ កបលក្ខណាសួគ៌សល់ស្រី ។

## បទភាគគតិ

និទានមាយើង បានយសថ្កុំថ្កើង សាន្តសម្រឹទ្ធី
ស្លេះទុកទើបថ្លែង សំដែងស្រដី ដំណាលអំពី
អ្នកនាយភេត្រា ។

បានមេកញ្ជើ ធ្លុះអរលលើ ទៅជាភរិយា
ដោយវាពុំមាន ធនធានទ្រព្យា លុះបានហើយវា
ធ្វើឆ្មើងធំក្រៃ ។

ស្លៀកខៀនស្លៀកព្រៃ ស្អាងខ្លួនបន្ដែ ផ្ចិតផ្គង់សព្វថ្ងៃ
អាងប្ដីមានទ្រព្យ ប្រដាក់ច្រើនក្រៃ ថាខ្លួនវាថ្លៃ
ឥតគេផ្ទឹមផង ។

វាពុំស្រដី ទ្រព្យធនអ្វីៗ ពុំបានសួនត្រង់
ស៊ីចាក់ស៊ីចោល បាចសាចជាម្ដង មានកូនមួយផង
និងនាយនោះនៃ ។

បើកូននោះជុះ មេកញ្ជើធ្លុះ ពុំលាងវិស័យ
ដូចអ្នកទាំងគ្រប់ អាងទ្រព្យច្រើនក្រៃ ហែកព្រៃថ្លៃៗ
ជូនអាចម៍ចោលទៅ ។



លង់លុះវែងឆ្ងាយ ក្សិណក្សត់អន្តរាយ ទ្រព្យទាំងសំពៅ
ប្រែជាអ្នកខ្សត់ ទុគ៌តអាសៅ លក់ទាំងសំពៅ
ស៊ីចាយអស់ហោង ។

ហេតុស្រីខាតលក្ខណ៍ ពុំចេះទុកដាក់ រក្សាសួនត្រង់
ឱ្យអាប់យសប្ដី អប្រិយកន្លង សព្វថ្ងៃនេះហោង
សុំទានគេស៊ី ។

កំសោយកំសត់ ហិនហោចទុគ៌ត ដើរដោយប្រឹថពី
ស្វែងរកសុំទាន សព្វឋានទិសទី ចិញ្ចឹមជីវី
ជីវិតសព្វថ្ងៃ ។

សុំទានរៀងទៅ ដូចដល់លំនៅ ផ្ទះមាយើងវៃ
នាងយល់អ្នកខ្សត់ ទុគ៌តក្រក្រៃ ស្មានអ្នកដទៃ
ហើយឱ្យទានទៅ ។

លុះគន់ជាក់លាក់ នាងស្គាល់ជាអ្នក ថៅនាយសំពៅ
ប្ដីដើមនៃនាង ទើបនាងថាទៅ ឱនាយសំពៅ
ម្ដេចដើរសុំទាន ។

បួរផ្ដាច់បោះបង់ អញឥតមានស ង្ស័យអញស្មោះស្មាន
និងកើតរបស់ ស័ក្ដិយសធនធាន ឥឡូវម្ដេចប្រាណ
ប្រែខ្លួនទទេ ។

ល្អពេកមុខថៅ ថៅនាយសំពៅ ដើរសុំទានគេ
ស្រឡាញ់ប្រពន្ធ ល្អលន់មុខមេ កញ្ជើធ្លុះទេ
ល្អពេកប្រាកដ ។

នេះហេតុលក្ខណ៍ស្រី គេចម្រើនប្ដី បរិបូណ៌បានបទ
ស្រីយើងចង្រៃ ពេកក្រៃប្រាកដ នៅនឹងអ្នកខ្សត់
ប្រែជាអ្នកមាន ។

មនុស្សខ្សត់ទាំងពីរ ឮហើយរមិល មើលនាងកល្យាណ
ស្គាល់ជាក់ហើយខ្មាស អាស្រូវភាសភាន ចៀសចេញទៅឋាន
លំនៅអាត្មា ។

មាយើងមានយស ឧត្តមខ្ពង់ខ្ពស់ ត្បិតភរិយា
យសយឺនពណ្ណរាយ កេ្តរ្តិ៍ឆ្ងាយសោះសា ប្រាកដប្រុះប្រា
កបកេរ្តិ៍វែងឆ្ងាយ ។

រីឯសភាព ដំណើរគិរកាព្យ មានពីព្រេងនាយ
បរមបុរាណ និទាននិយាយ អស់អាថ៌បរិយាយ
ចែកចប់ម្ល៉េះហោង ។